**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម**

**និងសំណង់**

លេខ៖ ១២២៩ ប្រក.មផ.ដនស

# ប្រកាសរួម

## ស្តីពី

## ការទប់ស្កាត់ការសាងសង់គ្មានលិខិតអនុញ្ញាត ឬការសាងសង់ខុសពីលិខិតអនុញ្ញាត

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៤/នស/៩៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ

-បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់

វាយអត្ថបទដោយ៖ លោក ឈឹម ទីណា

## សំរេច

**ប្រការ ១.~**

ប្រកាសនេះ មានគោលដៅពង្រឹងការអនុវត្តបទប្បញ្ញត្តិនានា ដែលទាក់ទងទៅនឹងវិស័យសំណង់ដើម្បីបង្កើនសោភ័ណភាព គុណភាព សុវត្ថិភាពសំណង់ ធានាបានបរិស្ថានល្អ និង ទប់ស្កាត់ការសាងសង់គ្មានលិខិតអនុញ្ញាតសាងសង់ ការសាងសង់ខុសពីលិខិតអនុញ្ញាត គ្មានលិខិតអនុញ្ញាតបើកការដ្ឋាន គ្មានលិខិតអនុញ្ញាតបិទការដ្ឋាន ឬវិញ្ញាបនប័ត្របញ្ជាក់ភាពត្រឹមត្រូវនៃសំណង់ ការរុះរើ និងជួសជុសដោយគ្មានលិខិតអនុញ្ញាត និងការជួសជុលខុសពីលិខិតអនុញ្ញាត ។

**ប្រការ ២.~**

អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន នៃក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋានជំនាញ នៃក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ និងអាជ្ញាធររាជធានី ខេត្ត ត្រូវសហការគ្នាដើម្បីធ្វើការណែនាំ និងផ្សព្វផ្សាយច្បាប់ អនុក្រឹត្យ ប្រកាស ប្រកាសរួម លិខិតបទដ្ឋាន និងឯកសារគតិយុត្តនានា ដែលពាក់ព័ន្ធ ទៅនឹងការគ្រប់គ្រងសំណង់គ្រប់ប្រភេទដល់ស្ថាប័ន អង្គភាព អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ អ្នកវិនិយោគទុន និងសាធារណជនឱ្យបានទូលំទូលាយ ដើម្បីចូលរួមអនុវត្តឱ្យមានប្រសិទ្ធភាព ។

**ប្រការ ៣.~**

មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី ខេត្ត មានភារកិច្ចដូចតទៅ៖

១-ទទួលខុសត្រូវតាមដានការអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តទាក់ទងនិង ការសាងសង់ និងឯកសារបច្ចេកទេសនានា នៅគ្រប់ការដ្ឋានសំណង់ទាំងអស់ក្នុងភូមិសាស្ត្ររបស់ខ្លួន

២-ចុះត្រួតពិនិត្យគ្រប់ការដ្ឋានសំណង់ជាប្រចាំ ទាំងសំណង់ដែលជាសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតដោយក្រសួង ទាំងសំណង់ដែលជាសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតដោយសាលារាជធានី ខេត្ត

៣-ក្នុងករណីពិនិត្យឃើញថា មានសំណង់មិនប្រក្រតីមន្ទីរត្រូវ៖

-រាយការណ៍ជាបន្ទាន់មកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ តាមគ្រប់រូបភាព ដើម្បីក្រសួង មានមូលដ្ឋានក្នុងការចេញលិខិតផ្អាកការដ្ឋានសំណង់ និងមានវិធានការតាមច្បាប់ក្នុងករណីពិនិត្យឃើញថា ការដ្ឋានសំណង់ដែលជាសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតដោយក្រសួង អនុវត្តខុសពីប្លង់បច្ចេកទេស និងចម្លងសេចក្តីរាយការណ៍ខាងលើនេះមួយច្បាប់ជូនសាលារាជធានី ខេត្ត ដើម្បីជ្រាបជារបាយការណ៍

-រាយការណ៍ជាបន្ទាន់មកសាលារាជធានី ខេត្ត តាមគ្រប់រូបភាពដើម្បីសាលារាជធានី ខេត្ត ចាត់វិធានការតាមច្បាប់ក្នុងករណីពិនិត្យឃើញថា ការដ្ឋានសំណង់ដែលជាសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតដោយសាលារាជធានី ខេត្ត អនុវត្តខុសពីប្លង់បច្ចេកទេស និងចម្លងសេចក្តីរាយកាណ៍ខាងលើនេះមួយច្បាប់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីជ្រាបជារបាយការណ៍ ។

**ប្រការ ៤.~**

អាជ្ញាធររាជធានី-ខេត្ត មានភារកិច្ចដូចតទៅ៖

-រក្សាសណ្តាប់ធ្នាប់សាធារណៈ នៅគ្រប់ការដ្ឋានសំណង់

-ចូលរួមទប់ស្កាត់ការសាងសង់ ការរុះរើ ជួសជុលគ្មានលិខិតអនុញ្ញាត ឬការសាងសង់ ការរុះរើ ជួសជុសខុសពីលិខិតអនុញ្ញាតតាមការស្នើសុំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី-ខេត្ត ។

**ប្រការ ៥.~**

ការផ្តល់លិខិតអនុញ្ញាតសាងសង់ និងជួសជុលសំណង់ នៃសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬអាជ្ញាធររាជធានី-ខេត្ត ស្របតាមអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់ ។

**ប្រការ ៦.~**

អគ្គនាយកដ្ឋានជំនាញ នៃក្រសួងទាំងពីរ និងអាជ្ញាធររាជធានី-ខេត្ត ត្រូវទទួលខុសត្រូវតាមដានត្រួតពិនិត្យនិងសហការឱ្យបានល្អ ដើម្បីអនុវត្តប្រកាសអន្តរក្រសួងនេះ ដោយតម្លាភាព ឱ្យមានប្រសិទ្ធភាព ។

**ប្រការ ៧.~**

អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គាធិការ នៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន នៃក្រសួងមហាផ្ទៃ អភិបាលរាជធានី-ខេត្ត អគ្គនាយក នៃអគ្គនាយកដ្ឋានជំនាញ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី-ខេត្ត ត្រូវអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ, ថ្ងៃទី២១ ខែ មេសា ឆ្នាំ ២០០៩

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី**
**នគរូបនីយកម្ម និង សំណង់**

<u>កន្លែងទទួល៖</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់គ្រង ស្ថាប័ន
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ
ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
-ខុទ្ទកាល័យលោកជំទាវឧបនាយករដ្ឋមន្ត្រី ម៉ែន សំអន
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប៊ិន ឈិន
“<u>ដើម្បីជូនជ្រាប</u>”
ដូចប្រការ៧
“ដើម្បីអនុវត្ត”
ឯកសារ-កាលវប្បវត្តិ

វាយអត្ថបទដោយ៖ លោក ឈឹម ទីណា